# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី១០ ធ្នូ ២០០៨



ការកើតវិបត្តិផ្លូវចិត្ត ឬរោគផ្លូវចិត្តនេះ មានទម្ងន់ណាស់ បើមិនឆាប់ដោះស្រាយទេ ទុកយូរទៅអាចខូចដល់ប្រព័ន្ធសរសៃប្រសាទ ដោយសារការព្រួយចិត្តដេកមិនលក់បាយមិនបាន ។ ដំបូងព្រួយផ្លូវចិត្ត វាឲ្យឥទ្ធិពលទៅលើផ្លូវកាយ ធ្វើឲ្យកាយទ្រុឌទ្រោមថមថយកម្លាំង ព្រោះកាយនិងចិត្តមានទំនាក់ទំនងគ្នា ។ បុគ្គលខ្លះមានវិបត្តិស្នេហា មិនបន្ទោសកំហុសខ្លួនឯងក្នុងបច្ចុប្បន្នទេ ទៅបន្ទោសព្រះព្រហ្មលិខិត ឬបន្ទោសកម្មពីអតីតជាតិ ។ ពិតមែនតែព្រះពុទ្ធពោលអំពីកម្មពីអតីតជាតិរបស់បុគ្គលមួយរូបៗ ប៉ុន្តែព្រះអង្គឲ្យគិតអំពីអំពើរបស់ខ្លួនក្នុងបច្ចុប្បន្នផង ក្រែងបច្ចុប្បន្នជឿខុស សេពគប់ខុស សំរេចចិត្តខុសនាំឲ្យខ្លួនទទួលរងទុក្ខវេទនាដូច្នេះ ។

ពេលនេះយើងមិនទាន់និយាយអំពីដំណោះស្រាយតាមបែបព្រះពុទ្ធសាសនា អំពីរោគផ្លូវចិត្តនេះទេ ។ យើងសូមនិយាយអំពីដំណោះស្រាយតាមវេជ្ជបណ្ឌិតខាងចិត្តវិទ្យាខ្លះ អំពីការកែរោគផ្លូវចិត្តនេះ ។ មធ្យោបាយនោះ គឺគេឲ្យអ្នកមានវិបត្តិផ្លូវចិត្តនោះទៅហាត់ប្រាណ ឲ្យដើរលេងកំសាន្ត ដើម្បីប្តូរអារម្មណ៍ និងការលួងលោមផ្លូវចិត្ត ។ មធ្យោបាយនេះយើងយល់ថា ពុំដោះស្រាយបញ្ហាចំហេតុដែលនាំឲ្យកើតទុក្ខឡើយ ព្រោះត្រឡប់ពីការដើរកំសាន្តវិញ សេចក្តីទុក្ខនៅដដែល ។ មធ្យោបាយមួយទៀត បើកើតទុក្ខខ្លាំង វេជ្ជបណ្ឌិតឲ្យថ្នាំដេកលក់រំងាប់អារម្មណ៍ស្ងប់មិនឲ្យគិតច្រើន ។ យើងទទួលស្គាល់ថា ថ្នាំអាចមានប្រសិទ្ធិ

ភាព គឺធ្វើឲ្យអ្នកមានវិបត្តិផ្លូវចិត្តស្ងប់បានមួយដងមួយគ្រាដែរ ប៉ុន្តែដល់ពេលអស់អំណាចថ្នាំ បញ្ហានៅដដែល អ្នកនោះនៅតែកើតទុក្ខដដែល ។ នេះពុំមែនជាវិធីដោះស្រាយ ដើម្បីឲ្យអ្នកនោះឈប់ព្រួយចិត្តឡើយ ។ នេះជាវិធីដោះស្រាយមិនចំបញ្ហាឡើយ ព្រោះអ្នកកើតទុក្ខព្រួយចិត្តនោះ ពិតជាមានហេតុណាមួយដែលនាំឲ្យកើតទុក្ខនោះ ។ យើងនៅចាំបាន មានរឿងមួយឈ្មោះរឿងជីវិតអ្នកស្រែ រឿងនេះទំនងជាចេញមកពីប្រទេសបារាំង អ្នកនិពន្ធជាតិខ្មែរ ផ្សាយចេញជាវីដេអូ ឃើញរូបភាពនិងដំណើររឿង ។ ដំណើររឿងដោយសង្ខេបថា គ្រួសារកសិករមួយ មានប្តីប្រពន្ធនិងកូនស្រីពនាក់ ។ ប្តីភ្ជួរស្រែមុតជើងនឹងដែកគោលមានរបួសយ៉ាងធ្ងន់ ។ ប្រពន្ធមិនបាននាំប្តីទៅមន្ទីរពេទ្យ ដើម្បីឲ្យព្យាបាលមុខរបួសតាមវិទ្យាសាស្ត្រទំនើបទេ បែរជាទៅឲ្យគ្រូខ្មែរផ្សំថ្នាំបូរាណ ស្មោះផ្តិត្រង់មុខរបួសនោះ ។ មុខរបួសត្រង់ជើងនោះកាន់តែហើមធំឡើង ដោយរុំនឹងក្រ-ណាត់មិនស្អាត ធ្វើឲ្យមេរោគចូលពីក្រៅទៅផង ប្តីនោះក៏ទទួលមរណភាពទៅ ។ បន្ទាប់ពីប្តីស្លាប់ នាងជាប្រពន្ធយំសោកបោកខ្លួន ដោយនឹកប្តីផង ដោយគិតថាបន្ទុកការងារនឹងត្រូវធ្លាក់មកលើខ្លួនផង ។ តាមឃើញដំណើររឿង នាងប្រពន្ធពុំមែនកើតទុក្ខតែមួយថ្ងៃពីរថ្ងៃហើយបាត់ទៅវិញទេ នាងកើតទុក្ខដើរទ្រហោយំគ្មានបាយគ្មានទឹក កូនយកបាយទៅបញ្ចុកក៏មិនព្រមទទួល ទៅជាវង្វេងវង្វាន់ឡប់ស្មារតី ។ មេភូមិនិងចាស់ទុំខ្លះនៅក្នុងភូមិ បានធ្វើទ្រុងធំមួយ ហើយចាប់ដាក់ក្នុងទ្រុងបិទទ្វារយ៉ាងជិតកុំឲ្យរត់ទៅណា ។ ដោយឃើញថា វិបត្តិផ្លូវចិត្តនោះគ្មានបានធូរស្រាលសោះ ទើបចាស់ទុំអ្នកនៅភូមិផងរបងជាមួយលួងលោមឲ្យជិះរទេះយកទៅមន្ទីរពេទ្យ ។ ក្នុងរឿងមិនបានបញ្ជាក់ថា ពេទ្យព្យាបាលបែបណាទេ ស្រាប់តែពីរបីថ្ងៃឃើញដឹករទេះត្រឡប់មកវិញ ឃើញនៅតែឆ្កួតដដែល ។ រឿងនោះត្រូវបញ្ចប់ដោយនាងនោះនៅតែឆ្កួតស្រែកឡូឡាពេញភូមិដដែល ។

លើករឿងនេះមកពិនិត្យមើលគំនិតអ្នកនិពន្ធ ដែលបញ្ចប់រឿងដោយឲ្យអ្នកឆ្កួតចិត្តនៅតែឆ្កួតដដែលដូចនេះ គ្មានតម្លៃអ្វីឡើយ ។ ដូចមធ្យោបាយដាក់ក្នុងទ្រុង មធ្យោបាយដឹកទៅមន្ទីរពេទ្យ ត្រឡប់មកវិញនៅតែឆ្កួតដដែល ។ យើងមិនដឹងថា អ្នកនិពន្ធនោះចង់ឲ្យរឿងរបស់ខ្លួនទៅជាយ៉ាងណាទេ ដើម្បីឲ្យអនុ-សាសន៍ដល់អ្នកទស្សនា ។ យើងក៏មិនដឹងថា អ្នកនិពន្ធនិងអ្នកដឹកនាំរឿង ជា

ពុទ្ធសាសនិកជន ឬក៏កាន់សាសនាណាមួយទេ ។ ការពិតនាងឆ្កួតចិត្តដោយនឹកប្តី និងអស់សង្ឃឹមក្នុងជីវិតនៅពេលដែលប្តីស្លាប់ទៅ ។ ការទៅមន្ទីរពេទ្យដើម្បីព្យាបាលរោគផ្លូវកាយ មិនអាចធ្វើឲ្យនាងបាត់ឆ្កួតឡើយ ។ បើអ្នកនិពន្ធរឿងនេះជាពុទ្ធសាសនិកជន គួរនាំនាងចូលទៅវត្តព្រះពុទ្ធសាសនា ដើម្បីឲ្យព្រះសង្ឃជួយពន្យល់ធម៌អាថ៌ ឲ្យនាងដកចិត្តចេញពីប្តីដែលស្លាប់ ឲ្យនាងពិចារណាកម្មផល ឲ្យពិចារណានូវសង្ខារ ដែលកើតឡើងហើយតែងតែស្លាប់ទៅវិញ ហើយតែងតែមានការព្រាត់ប្រាស់គ្នាជាធម្មតា ។ កាលណានាងពិចារណាឃើញភាពពិតជាសច្ចធម៌នេះ នាងនឹងបានជាសះស្បើយ បាត់ឆ្កួតផ្លូវចិត្ត ដោយសារឱសថគឺព្រះធម៌ ព្រោះសេចក្តីទុក្ខរបស់នាងកើតពីការស្រឡាញ់ប្តី ដែលបាត់បង់ជីវិតទៅ ។ បើរឿងនេះបញ្ចប់ដោយនាងបាត់ឆ្កួតដោយសារព្រះធម៌បែបនេះ ជារឿងមានតម្លៃដ៏ខ្ពង់ខ្ពស់ណាស់ ជាការលើកតម្លៃពិតរបស់ព្រះធម៌ព្រះពុទ្ធសាសនាផង ហើយជាការណែនាំឲ្យអ្នកទស្សនាបានដឹងរូបមន្តមួយ សំរាប់កែឬព្យាបាលរោគផ្លូវចិត្តផង ហើយស្របតាមទំនៀមទម្លាប់ខ្មែរដែលគោរពព្រះពុទ្ធសាសនាផង ។ នាងបដាចាមានវិបត្តិធ្ងន់ជាងនាងក្នុងរឿងជីវិតអ្នកស្រែនេះទៅទៀត តែព្រះពុទ្ធព្យាបាលឲ្យជាដោយឱសថ គឺព្រះធម៌ ។ រឿងនេះគ្មានឧត្តមគតិល្អសំរាប់ទស្សនាឡើយ ។

(នៅមានត)

❄ ❄

❄